# គោលគំនិតសំខាន់ដើម្បីយល់ពី

# ព្រះពុទ្ធសាសនា

- ព្រះពុទ្ធសាសនាចូលមកខ្មែរជំនាន់ការផ្សាយរបស់ព្រះបាទអសោកពុំទាន់ចម្រើនទេ ទាល់តែមកដល់សម័យការផ្សាយចេញពីកោះលង្កា ទើបចាប់ចម្រើនរុងរឿងឡើងពេញបន្ទុក ។
- ព្រះពុទ្ធសាសនា ជាពាក្យប្រៀនប្រដៅ ជាច្បាប់ធម្មជាតិ ពុំមែនជាសរណវត្ថុទេ ។
- ព្រះពុទ្ធសាសនាមានទ្រឹស្តីខុសគ្នាស្រឡះពីព្រហ្មញ្ញសាសនា តែដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា ជួយបង្កើនការយល់ឱ្យបានច្បាស់លាស់ទូលំទូលាយពីព្រះពុទ្ធសាសនា គួរតែរៀនអំពីព្រហ្មញ្ញសាសនាថែមទៀតផង ។
- ព្រះពុទ្ធសាសនា ជាផ្លូវនាំសត្វឱ្យបានសេចក្តីស្ងប់ ប្រយោជន៍ និង សេចក្តីសុខចម្រើន ។
- ព្រះពុទ្ធសាសនាមានធុរៈ (ការងារដែលត្រូវធ្វើក្នុងព្រះពុទ្ធសាសនា ឬ ការងារដែលត្រូវធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ) ចំនួន២យ៉ាងគឺគន្ថធុរៈជាហេតុ និង វិបស្សនាធុរៈជាផល ។
- ព្រះពុទ្ធសាសនាអាចជួយយឹតយោងបរិស័ទឱ្យទៅកាន់ឧត្តមភាពបានយ៉ាងពិតប្រាកដ ប្រសិនជាអ្នកនោះ ប្រព្រឹត្តតាមគោលធម៌ឱ្យបានត្រឹមត្រូវពេញលក្ខណៈ ។
- ព្រះពុទ្ធសាសនាឥតមានបំណងឱ្យបរិស័ទជឿតាមបីដូចជាទាសៈទេ គឺមានបំណងចង់ឱ្យបរិស័ទប្រើសេរីភាពក្នុងការត្រិះរិះពិចារណាតាមមនសិការរបស់ខ្លួន ។
- ព្រះពុទ្ធសាសនានឹងសាបសូន្យអន់ថយទៅជាថោកទាបបាន ក៏មកពីពុទ្ធបរិស័ទមិនប្រតិបត្តិធម៌ដោយគោរព មិនរៀនធម៌ដោយគោរព មិនទ្រទ្រង់ធម៌ដោយគោរព និងមិនពិចារណាធម៌ដោយគោរព ។
- ព្រះពុទ្ធសាសនាចែកសុខជា២យ៉ាងគឺ លោកិយសុខ (លាយឡំដោយទុក្ខ) និងបរមសុខ (ឥតលាយឡំដោយទុក្ខ) ។ គោលបំណងធំបំផុតរបស់ព្រះពុទ្ធសាសនា គឺការបាញ់ឆ្ពោះទៅរកបរមសុខ ។ ដើម្បីឱ្យបានសម្រេចបរមសុខ មនុស្សត្រូវដើរតាមផ្លូវកណ្តាលទាំង៨ប្រការ (មជ្ឈិមាបដិបទា) ។
- ព្រះពុទ្ធសាសនានឹងមានជីវិតរស់នៅបាន ដោយសារមានបរិស័ទយកចិត្តទុកដាក់ស្រឡាញ់ចូលចិត្តការសិក្សារៀនសូត្រធម៌វិន័យ និង ការប្រតិបត្តិតាមធម៌វិន័យឱ្យបានត្រឹមត្រូវតាមគន្លងធម៌ ។

- ព្រះពុទ្ធសាសនាជា និយ្យានិកធម៌ គឺជាធម៌សម្រាប់ដឹកនាំ យឹតយោង និង ស្រោចស្រង់សត្វឱ្យរួចចាកទុក្ខភ័យក្នុងវដ្តសង្សារ ។
- ព្រះពុទ្ធសាសនាមានធាតុផ្ទាល់របស់ខ្លួនដាច់មុខខុសប្លែកពីសាសនាដទៃ គឺ អរិយសច្ចៈ៤ប្រការ ។
- ព្រះពុទ្ធសាសនារកសេចក្ដីសុខនៅនាលោកនេះផង និងនៅឯបរលោកផង ចំណែកវិទ្យាសាស្ត្ររកសេចក្ដីសុខបានតែក្នុងលោកនេះតែម្យ៉ាង ។
- ព្រះពុទ្ធសាសនានិយាយតែអំពីកម្មដែលមានចេតនា (ចេតនាកម្ម) គឺជាកម្មដែលធ្វើហើយពិតជាឱ្យផលវិបាកដល់ខ្លួនវិញជាដាច់ខាត ។ ឯកម្មមិនមានចេតនា ពុំមានចែងទុកក្នុងព្រះពុទ្ធសាសនាទេ ។
- ព្រះពុទ្ធសាសនាជាសាសនារចនាមនុស្សឱ្យចម្រើនខាងសីលធម៌ ព្រមទាំងគុណធម៌ លះបង់នូវបាបធម៌គ្រប់យ៉ាង ក្នុងគោលបំណងលុបបំបាត់នូវទុក្ខលំបាកវេទនា រហូតដល់ផុតជាតិ ជរា ព្យាធិមរណៈ ដើម្បីនិព្វាន ។
- ព្រះពុទ្ធសាសនាអាចចម្រើនថ្កុំថ្កើងរុងរឿងបាន ដោយពុទ្ធបរិស័ទប្រកាន់ធម៌វិន័យដោយគោរព ៥យ៉ាង គឺ ស្ដាប់ រៀនកត់ចំណាំ ត្រិះរិះពិចារណាឱ្យយល់ ដឹងហើយប្រតិបត្តិតាម ។
- ព្រះពុទ្ធសាសនាបង្រៀនថា មនុស្សខ្លះដែលរស់នៅក្នុងលោកសព្វថ្ងៃនេះ ក៏អាចមានឈ្មោះថាជាទេវតាបានដែរ ឱ្យតែអ្នកនោះមានទេវធម៌នៅក្នុងខ្លួន ។
- ព្រះពុទ្ធសាសនាមានលក្ខណៈពិសេស៤យ៉ាងសម្រាប់សំគាល់ គឺ លក្ខណៈប្រាកដនិយម លក្ខណៈវិចារណនិយម លក្ខណៈមនុស្សនិយម និង លក្ខណៈសាកល ។
- ព្រះពុទ្ធសាសនាចាត់មិច្ឆាទិដ្ឋិ ថាមានទោសខ្លាំងជាងគេបំផុត ព្រោះវាជាឫសគល់នៃបាបអកុសលគ្រប់ជំពូក ។ មនុស្សមិច្ឆាទិដ្ឋិពិបាកកែណាស់ អាក្រក់ជាងមនុស្សពាល ។
- ព្រះពុទ្ធសាសនាបានចែងថា មគ្គទាំង៨ កាលបើរួមចូលគ្នាហើយ អាចធ្វើបុគ្គលដែលប្រតិបត្តិតាមនោះឱ្យធ្លាក់ចុះក្នុងប្រឡាយនៃសេចក្ដីសុខ គឺ ពីលោកិយសុខរហូតដល់បរមសុខ ។
- ព្រះពុទ្ធសាសនាដែលនឹងប្រតិស្ឋានចាក់ឫសកែវជាប់ស៊ប់ឥតកម្រើកនោះ លុះត្រាតែពុទ្ធបរិស័ទបានសិក្សាធម៌អាចចេះចាំរត់មាត់ស្ទាត់ជំនាញ គោរពព្រះវិន័យឱ្យបានម៉ត់ចត់ ហើយអាចពន្យល់បង្ហាត់បង្ហាញបង្រៀនគ្នាបានផង ។
- ព្រះពុទ្ធសាសនាពន្យល់ពីអរិយទ្រព្យ៧ប្រការយ៉ាងក្បោះក្បាយថា កាលបើទ្រព្យខាងក្នុងមានហើយទ្រព្យខាងក្រៅនឹងកើតមានឯង ។

- ព្រះពុទ្ធសាសនាចែកមនុស្សជា៥ពួក ទៅតាមកម្មដែលខ្លួនបានធ្វើ គឺ មនុស្សនរក មនុស្សតិរច្ឆាន មនុស្សប្រេត មនុស្សមនុស្ស និង មនុស្សទេវតា ។
- ព្រះពុទ្ធសាសនាជាសាសនាដំបូងបំផុតដែលបានបង្រៀនមនុស្សឱ្យបញ្ឈប់នូវ ការជិះជាន់សង្កត់សង្កិនប្រមាថមើលងាយគ្នា ព្រោះតែរឿង (វណ្ណៈ)ដែលគេបង្កើតឡើងពុំសមហេតុផល ។
- ព្រះពុទ្ធសាសនាកើតក្រោយព្រហ្មញ្ញសាសនាជាងមួយពាន់ឆ្នាំ តែទស្សនវិជ្ជាព្រះពុទ្ធសាសនាមានអត្ថន័យព្រមទាំងអត្ថរសសែនជ្រាលជ្រៅក្រៃលែង ជាងព្រហ្មញ្ញសាសនាឆ្ងាយណាស់ ។
- ព្រះពុទ្ធសាសនាបានឱ្យតម្លៃយ៉ាងខ្ពស់ត្រដែតទៅលើការងារថា មានតែការងារមួយទេដែលមានភាពស័ក្តិសិទ្ធិអាចជួយបន្ធូរសេចក្តីទុក្ខព្រួយ និង ជួយបង្កើតសេចក្តីសុខសុភមង្គលរហូតដល់សុខខ្ពង់ខ្ពស់ ដែលហៅថានិព្វាន ។
- ព្រះពុទ្ធសាសនាជាសាសនារបស់មនុស្ស មិនមែនជាសាសនារបស់ទេវតាទេ ។ អ្នកចេះពុទ្ធសាសនារស់នៅបានស្រួលក្នុងសង្គមមនុស្ស ដូច្នេះយល់ព្រះពុទ្ធសាសនា គឺយល់មនុស្ស ។
- ព្រះពុទ្ធសាសនាហាមមិនឱ្យផឹកស្រាជាដាច់ខាត បើអាចចៀសបាន ទោះជាផឹករបៀបណាក៏ដោយ (ផឹកមិនឱ្យស្រវឹងខ្លាំង ផឹកជាកិត្តិយស ផឹកឱ្យឆ្ងាញ់បាយ ផឹកបំបាត់ទុក្ខ ផឹកឱ្យក្លាហានផឹកឱ្យគេសរសើរ) ព្រោះវាជាហេតុនៃសេចក្តីប្រមាទ ដែលជាប្រភពនៃអំពើអាក្រក់គ្រប់បែបយ៉ាង ។
- ព្រះពុទ្ធសាសនានិយាយតែពីសេចក្តីពិតរបស់ធម្មជាតិ ហេតុបច្ច័យរបស់ធម្មជាតិ មិនបាននិយាយតាមលទ្ធិ ឬ តាមវាទៈរបស់គ្រូអាចារ្យ ឬ អាទិទេពណាឡើយ ។
- ព្រះពុទ្ធសាសនាច្រើនតែមានទំនាស់គ្នានឹងគំនិតបុថុជ្ជនអ្នកមានកិលេសក្រាស់ ពេញដោយលោភៈ ទោសៈ មោហៈ ។ លុះតែជនណាដែលប្រកបដោយប្រាជ្ញាចាស់ក្លា ទើបអាចស្តាប់ធម៌វិន័យបាន ទើបកើតសទ្ធាជឿតាមបាន ទើបចូលមកអង្គុយជិតសង្គមពុទ្ធសាសនាបាន ។
- ព្រះពុទ្ធសាសនារីកចម្រើនខ្លាំងណាស់នៅសម័យពុទ្ធកាល ព្រោះបុព្វហេតុនៃធម្មទានយ៉ាងសស្រាក់សស្រាំរបស់ព្រះសម្មាសម្ពុទ្ធ និងព្រះអរិយសាវ័ករបស់ព្រះអង្គ ។ ធម្មទានជាអាយុជីវិតរបស់ព្រះពុទ្ធសាសនា ព្រមទាំងញ៉ាំងព្រះពុទ្ធសាសនា ឱ្យចម្រើនរុងរឿងឋិតថេរជាយូរអង្វែង ។ កំពូលនៃធម្មទាន គឺ សំដែងពីអរិយសច្ចៈ៤ប្រការ ។

- ព្រះពុទ្ធសាសនាពុំបានប្រកាន់យកបញ្ញាដែលមានមកពីកំណើតថា ជាបញ្ញាជាន់ខ្ពស់ទេ តែបានប្រកាន់យកបញ្ញាដែលកើតមកពីការសិក្សារៀនសូត្រ ឬ ការប្រតិបត្តិធម៌ ឬ ការអនុវត្តន៍ថាជាបញ្ញា ជាន់ខ្ពស់បំផុត ។
- ព្រះពុទ្ធសាសនាទូន្មានឱ្យត្រាច់តាមផ្លូវកណ្ដាលដែលហៅថា មជ្ឈិមាបដិបទា ។ ការទូន្មានឱ្យស្វែងរកសុខក្នុងកាមគុណ៥ និង ការធ្វើបាបរូបកាយខ្លួនឯង ទាំងពីរនេះមិនមែនជាព្រះពុទ្ធសាសនាទេ ។
- ព្រះពុទ្ធសាសនាពន្យល់ថា មានតែព្រះនិព្វានទេដែលអាចឱ្យមនុស្សរកឃើញនូវបរមសុខ ។ ទោះបីពុំអាចសម្រេចនូវឧត្ដមគតិនេះក៏ដោយ ការធ្វើដំណើរទៅតាមតម្រាយផ្លូវព្រះនិព្វានក៏អាចរកឃើញនូវសុខៈខ្លះៗបានដែរ ៕